**អង្គភាពគាំពារជនរងគ្រោះរៀបចំវេទិកាដើមបណ្តឹងរដ្ឋប្បវេណីក្នុងក្រុងបាត់ដំបង**

*អង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អវតក) នាថ្ងៃនេះបានរៀបចំវេទិកា ដែលមានរយៈពេលពីរថ្ងៃក្នុងក្រុងបាត់ដំបង សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន២៨០នាក់ ក្នុងសំណុំរឿង០០២។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះមកពីខេត្តបាត់ដំបង បន្ទាយមានជ័យ និងពោធិ៍សាត់។*

*វេទិកានេះផ្តល់ឱកាសឲ្យដើមបណ្តឹងរដ្ឋប្បវេណីសិក្សាអំពីការវិវឌ្ឍថ្មីៗនៅតុលាការ និងការរីកចម្រើនក្នុងករណីផ្ទាល់ខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ។ វេទិកានេះក៏ផ្តល់ឱកាសផងដែរដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការជួបមេធាវីរបស់ខ្លួន និងពិភាក្សាអំពីការចូលរួមរបស់ខ្លួនក្នុងសំណុំរឿង០០២ និងការរំពឹងទុករបស់ខ្លួន។*

*ក្នុងឱកាសបើកវេទិកា ឯកឧត្តម ក្រាញ់ តូនី ប្រធានស្តីទីនៃការិយាល័យរដ្ឋបាលនៃអវតក បានគូសបញ្ជាក់អំពីសារៈសំខាន់នៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ឯកឧត្តមមានប្រសាសន៍ថា "នេះគឺជាលើកដំបូងក្នុងតុលាការ ដែលគាំទ្រដោយសហគមន៍អន្តរជាតិ ដែលជនរងគ្រោះមានសិទ្ធិពេញលេញក្នុងការចូលរួមក្នុងនាមជាភាគីក្នុងដំណើរការនីតិវិធី"។ ឯកឧត្តមបញ្ជាក់ថា គោលបំណងចម្បងនៃការិយាល័យរដ្ឋបាលគឺគាំទ្រដល់ការអនុវត្តដ៏មានប្រសិទ្ធភាពនៃសិទ្ធិរបស់ភាគីនៅចំពោះមុខតុលាការ។ ឯកឧត្តម ក្រាញ់ តូនី បានឆ្លៀតឱកាសនេះប្រគល់ជូនសៀវភៅសាលក្រមក្នុងសំណុំរឿង០០១ ប្រឆាំងនឹង កាំង ហ្គេកអ៊ាវ ដល់លោកនៅ យ៉ារ័ត្ន ប្រធានតុលាការខេត្តបាត់ដំបង ដើម្បីទុកជាឯកសារយោងសម្រាប់ចៅក្រមនៅតុលាការខេត្ត។ លោក នៅ យ៉ារ័ត្ន បានប្រកាសថា ខ្លួនលោកផ្ទាល់ "ពេញចិត្តយ៉ាងខ្លាំង" នឹងសាលក្រមប្រឆាំងនឹង កាំង ហ្គេកអ៊ាវ។*

*ឯកឧត្តម សៀង ស៊ុតថង អភិបាលរងខេត្តបាត់ដំបង ក៏បានកត់សម្គាល់ផងដែរអំពីសារៈសំខាន់នៃដំណើរការនីតិវិធី ដែលអនុញ្ញាតឲ្យជនរងគ្រោះបន្តកសាងជីវិតរបស់ខ្លួនក្នុងសហគមន៍ ហើយឯកឧត្តមបានថ្លែងអំណរគុណដល់តុលាការក្នុងការរៀបចំវេទិកាដើមបណ្តឹងរដ្ឋប្បវេណីលើកទីមួយនេះក្នុងភូមិភាគនេះ។*

*វេទិកានេះប្រព្រឹត្តទៅនៅថ្ងៃទី៣០ និង៣១ ខែសីហា និងបានចូលរួមផងដែរដោយអង្គការសង្គមស៊ីវិល ដែលជួយដល់ជនរងគ្រោះក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងពាក្យបណ្តឹង។*